THE SCHOOL DISTRICT OF PHILADELPHIA

# ការណែនាំសម្រាប់មាតាបិតា

## ការធ្វើតេស្តតាមវិធី Star សម្រាប់ថ្នាក់មត្តេយ្យ ដល់ ទី៨

### តើ Star ជាអ្វី?

នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា យើងប្រើ Star ជាឧបករណ៍ដើម្បីវាស់ស្ទង់ជំនាញគណិតវិទ្យា និងការអាន សម្រាប់សិស្សទាំងអស់។ ការវាយតម្លៃតាមវិធី Star គឺជាការធ្វើតេស្តខ្លីដែលផ្តល់ឱ្យគ្រូនូវទិន្នន័យសិក្សា។ សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៥ នឹងចំណាយពេលប្រហែល ៣០ នាទី រៀងរាល់ត្រីមាស ដើម្បីធ្វើការវាយតម្លៃតាមវិធី Star។ ទិន្នន័យដែលបានពីការវាយតម្លៃតាមវិធី Star ជួយណែនាំដល់ការអនុវត្តវិធីសាស្ត្រដែលនឹងបង្កើនលទ្ធផលរបស់សិស្ស និងជួយឱ្យសាលារបស់យើងសម្រេចតាមគោលដៅដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាលអប់រំ។

### តើគ្រូធ្វើអ្វីជាមួយការវាយតម្លៃតាមវិធី Star?

គ្រូពិនិត្យមើលទិន្នន័យដែលពួកគេទទួលបានពីការធ្វើតេស្តតាមវិធី Star ដើម្បីស្វែងយល់ពីអ្វីដែលសិស្សដឹងរួចទៅហើយ និងអ្វីដែលពួកគេត្រៀមខ្លួនរៀនបន្ទាប់ទៀត ដើម្បីវាស់ស្ទង់ការរីកចម្រើនក្នុងការសិក្សា និងសម្រេចថាតើសិស្សណាត្រូវការការគាំទ្របន្ថែម។ គ្រូអាចប្រើព័ត៌មានដែលបានពីការធ្វើតេស្តតាមវិធី Star ដើម្បីណែនាំការបង្ហាត់បង្រៀនសម្រាប់ថ្នាក់ទាំងមូល សម្រាប់ក្រុមសិស្ស និងសម្រាប់សិស្សម្នាក់ៗ។ ការវាយតម្លៃតាមវិធី Star ផ្អែកលើការស្រាវជ្រាវ ហើយបានបង្ហាញឱ្យឃើញថាជួយគ្រូណែនាំសិស្សម្នាក់ៗទៅកាន់ផ្លូវសិក្សាខុសៗគ្នារបស់ពួកគេ។ [1]

### តើការវាយតម្លៃតាមវិធី Star ណាមួយដែលកូនខ្ញុំនឹងធ្វើ?

សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៥ នឹងធ្វើតេស្តតាមកុំព្យូទ័រ និងការវាស់ស្ទង់ដែលផ្អែកលើកម្មវិធីសិក្សា (computer adaptive tests and curriculum-based measures) រួមគ្នា ក្នុងអំឡុងឆ្នាំសិក្សា។ ការធ្វើតេស្តតាមកុំព្យូទ័រ (computer adaptive tests) កែសម្រួលផ្អែកទៅលើចម្លើយនីមួយៗដែលកូនរបស់លោកអ្នកផ្តល់ឱ្យ។ នេះជួយគ្រូឱ្យទទួលព័ត៌មានដែលល្អបំផុតដើម្បីជួយកូនរបស់លោកអ្នកក្នុងអំឡុងពេលធ្វើតេស្តខ្លីនេះ។ សិស្សថ្នាក់មត្តេយ្យ ថ្នាក់ទី១ និងសិស្សថ្នាក់ទី២ ដែលមិនចេះអានដោយខ្លួនឯងបាននឹងធ្វើតេស្តតាមវិធី Star Lite Literacy។ សិស្សថ្នាក់ទី២ ដែលអាចអានដោយខ្លួនឯងបាន និងសិស្សថ្នាក់ទី៣ ដល់ ទី៥ នឹងធ្វើតេស្តតាមវិធី Star Reading និង Star Math។

ការវាស់ស្ទង់ដែលផ្អែកលើកម្មវិធីសិក្សា (curriculum-based measures) គឺជាការធ្វើតេស្តរយៈពេលមួយនាទីៗដែលនឹងត្រូវធ្វើមួយទល់មួយ។ ទាំងនេះនឹងត្រូវប្រើដើម្បីវាស់ស្ទង់លទ្ធផលនៃជំនាញជាក់លាក់របស់សិស្សសម្រាប់ គណិតវិទ្យា និងការអាន។ សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៥ នឹងធ្វើតេស្តតាមវិធី curriculum-based measures សម្រាប់ការអាន។ លើសពីនេះទៀត សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៣ នឹងធ្វើតេស្តតាមវិធី curriculum-based measures សម្រាប់គណិតវិទ្យា។

### តើសំណួរប្រភេទណាដែលមាននៅលើការវាយតម្លៃតាមវិធី Star?

Star Early Literacy មាន ២៧ សំណួរ ដែលបានរៀបចំឡើងសម្រាប់សិស្សដែលមិនអាចអានដោយខ្លួនឯងបាន (តេស្តនេះត្រូវអានខ្លាំងៗឱ្យសិស្សស្តាប់)។ ក្នុងចំណោមអ្វីៗទាំងនេះ មានអ្វីៗមួយចំនួនដើម្បីវាយតម្លៃជំនាញគណិតវិទ្យា។ Star Reading និង Star Math តេស្តនីមួយៗមាន ៣៤ សំណួរ ដែលមានចម្លើយជាច្រើនសម្រាប់ជ្រើសរើស (multiple choice questions)។ ដោយសារការវាយតម្លៃតាមវិធី Star Early

---

[1] Renaissance. (2020). Research Foundation for Star Adaptive Assessments. https://doc.renlearn.com/KMNet/R001480701GCFBB9.pdf.

### តើពិន្ទុនៃការធ្វើតេស្តតាមវិធី Star មានន័យដូចម្ដេច?

កូនលោកអ្នកនឹងទទួលពិន្ទុនៃការធ្វើតេស្តតាមវិធី Star ជាច្រើនប្រភេទ៖

The **scale score** គឺជាពិន្ទុផ្អែកលើលទ្ធផលទូទៅ។

The **percentile ranking** បង្ហាញឱ្យឃើញនូវលទ្ធផលរបស់កូនលោកអ្នកប្រៀបធៀបទៅនឹងលទ្ធផលរបស់សិស្សដទៃទៀតទូទាំងប្រទេស ក្នុងថ្នាក់ដូចគ្នា។

The **benchmark category** បង្ហាញលោកអ្នកថាតើក្រុមណាដែលកូនរបស់លោកអ្នកនឹងត្រូវដាក់ឱ្យរៀន យោងទៅលើលំដាប់ភាគរយរបស់ពួកគេ។

The **grade equivalence** បង្ហាញឱ្យឃើញនូវលទ្ធផលនៃកម្រិតថ្នាក់របស់កូនលោកអ្នក។

The student growth percentile វាស់ស្ទង់ថាតើកូនរបស់លោកអ្នកបានរីកចម្រើនប៉ុណ្ណា។

The instructional reading level បង្ហាញពីកម្រិតថ្នាក់ដែលកូនរបស់លោកអ្នកអាចអានដើម្បីសិក្សា។

The **Lexile level** ផ្ដល់ឱ្យគ្រូរបស់កូនលោកអ្នកនូវការយល់ដឹងបន្ថែមអំពីសមត្ថភាពក្នុងការអាន និងភាពលំបាកនៃសៀវភៅដែលពួកគេអាចអានដោយខ្លួនឯង។

សម្រាប់ curriculum-based measures សិស្សនឹងទទួលពិន្ទុត្រូវក្នុងមួយនាទីៗដែលបង្ហាញឱ្យឃើញនូវចំនួនដែលពួកគេបានឆ្លើយត្រូវ។

Literacy ការអាន និងគណិតវិទ្យា គឺជាការប្រឡងតាមកុំព្យូទ័រ កម្រិតពិបាកនៃសំណួរនីមួយៗ នឹងផ្លាស់ប្ដូរយោងទៅលើទង្វើរបស់សិស្សបានល្អប៉ុណ្ណាក្នុងការវាយតម្លៃ។ នោះគឺ នៅពេលដែលសិស្សឆ្លើយសំណួរត្រូវច្រើន សំណួរកាន់តែពិបាកឡើង ហើយនៅពេលដែលសិស្សឆ្លើយសំណួរត្រូវតែបន្តិចបន្តួច សំណួរក្នុងតេស្តនឹងមិនសូវពិបាកទេ។ ភាពលំបាកនៃសំណួរមានចាប់ពីកម្រិតថ្នាក់ទីមួយ រហូតដល់ កម្រិតថ្នាក់ទីដប់ពីរ។

ការវាស់ស្ទង់ដែលផ្អែកលើកម្មវិធីសិក្សា (curriculum-based measures) គឺជាការធ្វើតេស្តរយៈពេលមួយនាទីៗដែលវាយតម្លៃពីជំនាញមូលដ្ឋានខុសៗគ្នា។ តេស្តទាំងនេះនឹងត្រូវដាក់ឱ្យធ្វើមួយទល់មួយ ហើយនឹងវាស់ស្ទង់ជំនាញជាក់លាក់ ដូចជាការចេះ អក្សរ បូក ដក និងគុណ។

## តើការវាយតម្លៃតាមវិធី Star ជួយអ្វីដល់កូនខ្ញុំ?

តាមរយៈនៃការបញ្ជាក់យ៉ាងច្បាស់នូវអ្វីៗដែលកូនលោកអ្នកចេះ គ្រូអាចកំណត់ការបង្ហាត់បង្រៀនរបស់កូនលោកអ្នកផ្ទាល់ដើម្បីធ្វើឱ្យពួកគេមានការរីកចម្រើនក្នុងការសិក្សា។ លើសពីនេះទៀត ពេលវេលាធ្វើតេស្តខ្លីធានាថាកូនលោកអ្នកមានពេលច្រើនសម្រាប់សិក្សា ហើយចំណាយពេលតិចសម្រាប់ការធ្វើតេស្ត។

## តើការធ្វើតេស្តតាមវិធី Star ប៉ះពាល់ដល់ពិន្ទុរបស់កូនខ្ញុំដែរឬទេ?

ការធ្វើតេស្តនេះមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ។ លទ្ធផលត្រូវប្រើដើម្បីជួយគ្រូបំពេញតម្រូវការរបស់សិស្សទាំងអស់តែប៉ុណ្ណោះ។ នេះជាលទ្ធផលដែលអាចជួយឱ្យពិន្ទុរបស់កូនលោកអ្នកមានភាពកាន់តែប្រសើរឡើង ដោយសារតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានកំណត់ ហើយការបង្ហាត់បង្រៀនត្រូវបានកែសម្រួលទៅតាមនោះ។

## តើពេលណាទើបកូនខ្ញុំធ្វើតេស្តតាមវិធី Star របស់ពួកគេ?

សាលា និងគ្រូ នឹងកំណត់ពេលវេលាធ្វើតេស្តក្នុងអំឡុងពេលបួនខាងក្រោមនេះ៖

- Star Fall (តម្រូវ)៖ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២៣
- Star Winter (តម្រូវ)៖ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២៣ ដល់ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៤
- Star Spring (តម្រូវ)៖ ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២៤

## តើការធ្វើតេស្តតាមវិធី Star នឹងត្រូវធ្វើទៅដោយរបៀបណា?

សិស្សនឹងធ្វើតេស្តក្នុងអំឡុងពេលធ្វើតេស្តបួន។ ការវាយតម្លៃតាមកុំព្យូទ័រ (computer adaptive assessments) នឹងធ្វើឡើងតាមការប្រើបច្ចេកវិទ្យានៅក្នុងសាលា។ ការវាស់ស្ទង់ដែលផ្អែកលើកម្មវិធីសិក្សា (curriculum-based measures) អាចធ្វើឡើងតាមការប្រើបច្ចេកវិទ្យា ការប្រើក្រដាស ឬតាមការរួមបញ្ចូលគ្នាទាំងពីរ។

## តើខ្ញុំអាចរៀបចំកូនរបស់ខ្ញុំឱ្យទទួលជោគជ័យក្នុងការធ្វើតេស្តតាមវិធី Star ដោយរបៀបណា?

សូមធ្វើយ៉ាងណាឱ្យសិស្សសម្រាកឱ្យបានច្រើន មុនពេលទៅសាលានៅថ្ងៃដែលពួកគេធ្វើតេស្តតាមវិធី Star។ ជំរុញពួកគេឱ្យខំធ្វើកិច្ចការរបស់ពួកគេឱ្យអស់ពីសមត្ថភាព ហើយរំលឹកពួកគេថា វានឹងជួយគ្រូរបស់ពួកគេឱ្យបំពេញនូវតម្រូវការសិក្សាផ្ទាល់ខ្លួនរបស់សិស្សឱ្យកាន់តែប្រសើរជាងមុន។

## តើខ្ញុំអាចមើលលទ្ធផលពីការធ្វើតេស្តនៅទីណា?

លទ្ធផលពីការធ្វើតេស្តនឹងមានក្រោយពេលផុតរយៈពេលធ្វើតេស្តនីមួយៗ តាមរយៈ គេហទំព័រមាតាបិតា (Parent Portal)។ ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការស្វែងយល់អំពីលទ្ធផល សូមទាក់ទងគ្រូរបស់សិស្សលោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីចូលមើលគេហទំព័រមាតាបិតា សូមមើលនៅត្រង់នេះ៖ [https://www.philasd.org/face/fr/parent-and-family-portal/](https://www.philasd.org/face/fr/parent-and-family-portal/) ។